LASED

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច

# ការទទួលខុសត្រូវ និងសិទ្ធិសំខាន់ៗទាំង៦ចំណុចរបស់អ្នកទទួលសម្បទានដីសង្គមកិច្ច ពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) (អនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ១៨)



អ្នកទទួលសម្បទានដីសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារត្រូវដាំដំណាំឲ្យបានជាប់លាប់នៅលើដីនោះក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីបានទទួលដី ហើយត្រូវបន្តប្រើប្រាស់ដីនោះស្របតាមលក្ខខណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ច។



ប្រសិនបើគ្មានសំណង់លំនៅឋាននៅលើសម្បទានដីសង្គមកិច្ចនោះទេ អ្នកទទួលដីត្រូវសាងសង់យ៉ាងហោចណាស់ផ្នែកណាមួយនៃលំនៅឋានអចិន្ត្រៃយ៍ក្នុងអំឡុងពេល បី (៣) ខែ បន្ទាប់ពីទទួលបានដី ហើយសមាជិកគ្រួសារម្នាក់ត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍នៅលើដីនោះយ៉ាងតិចប្រាំមួយ (៦) ខែក្នុងឆ្នាំនីមួយៗ។



អ្នកទទួលដីមិនអាចលក់ ជួល បរិច្ចាគ ឬឲ្យគេចាំជំនួស សម្បទានដីសង្គមកិច្ចនេះ បានឡើយនៅក្នុងរយៈពេលប្រាំ (៥) ឆ្នាំ ដំបូងនៃការអនុវត្តតាមកិច្ចសន្យាសម្បទានដីសង្គមកិច្ច។



ប្រសិនបើអ្នកទទួលសម្បទានដីសង្គមកិច្ចណាម្នាក់ស្លាប់នៅពេលកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ទាយាទនៅក្នុងគ្រួសាររបស់គាត់អាចបន្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរហូតដល់ប្រាំ (៥) ឆ្នាំ ទើបមានសិទ្ធិកម្មសិទ្ធិលើដីនោះ។



បន្ទាប់ពីអនុវត្តបានយ៉ាងត្រឹមត្រូវតាមលក្ខខណ្ឌនៃកម្មវិធីសម្បទានដីសង្គមកិច្ចរយៈពេលប្រាំ (៥) ឆ្នាំ អ្នកទទួលដីមានសិទ្ធិកម្មសិទ្ធលើដីនោះ ហើយអាចដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីស្របតាមនីតិវិធីដែលបានកំណត់នៅក្នុងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។



ប្រសិនបើអ្នកទទួលសម្បទានដីសង្គមកិច្ចខកខានមិនបានបំពេញតាមលក្ខខណ្ឌកាន់កាប់ និងប្រើប្រាស់សម្បទានដីសង្គមកិច្ចទេ ដីនោះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញដើម្បីធ្វើការបែងចែកសាជាថ្មី។

សម្រាប់ព័ត៌មានបន្ថែមពីសម្បទានដីសង្គមកិច្ច និងគម្រោង LASED សូមទំនាក់ទំនង:
- មេភូមិ ឬ មេឃុំ
- ការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីរាជធានី/ខេត្ត
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ(អគសសជ)

បោះពុម្ពដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ចំនួន ២៥០សន្លឹក, នៅខែ កញ្ញា ឆ្នាំ ២០១២
អាសយដ្ឋាន: អគារលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ,
Email: lased@ezecom.com.kh

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ក្រសួងមហាផ្ទៃ

THE WORLD BANK

WATHNAKPHEAP

COOPERATION KINGDOM OF CAMBODIA FEDERAL REPUBLIC OF GERMANY

giz

CONSULT GOPA

គាំទ្រដោយ ក្រសួងអភិវឌ្ឍន៍ និង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៃសហព័ន្ធសាធារណរដ្ឋអាល្លឺម៉ង់ (BMZ) តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ GIZ
(Deutsche Gesellschaft für Internationale Zusammenarbeit GmbH)